# វិញ្ញាណបរិសុទ្ធ

# នៃព្រះ

# *The Holy Spirit*

# *of God*

ដោយ ប៊ូ ឈុំ

សូមឆែក: *Sabbath Reflections.org*

# ឆ្លុះបញ្ចាំងថ្ងៃសប្ប័ទ

## ឬ ទំព័រខ្មែរ


Tel: 016 509 779/ 011 435 441/ 097 990 6244

E-mail:chumbou2020@gmail.com

បទគម្ពីរចម្លងក្នុងខិត្តប័ណ្ណនេះ
ដកស្រង់ចេញពីគម្ពីរបោះពុម្ព ឆ្នាំ១៩៥៤

«ពួកស្ងួនភ្ងាអើយ កុំឲ្យជឿគ្រប់ទាំងវិញ្ញាណឡើយ ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឲ្យបានដឹងជាមកពីព្រះ ឬមិនមែន ដ្បិតមានហោរាក្លែងក្លាយជាច្រើនកើតមកក្នុងលោកីយនេះហើយ យើងនឹងសំគាល់វិញ្ញាណនៃព្រះបានដូច្នេះ គឺអស់ទាំងវិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម គឺវិញ្ញាណនោះហើយ ដែលមកពីព្រះ តែវិញ្ញាណណាដែលមិនព្រមថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាមទេ នោះមិនមែនមកពីព្រះឡើយ គឺជាវិញ្ញាណរបស់អាទទឹងនឹងព្រះគ្រីស្ទវិញ ដែលអ្នករាល់គ្នាបានឮនិយាយថា ត្រូវមក តែឥឡូវនេះ ក៏នៅក្នុងលោកីយហើយ» (១យ៉ូហាន៤:១-៣)

**ខ្មែរស្ងួនភ្ងាហៅចេញសំរាប់ព្រះ**

**Khmer Brethren Called for God**

**ទំនាក់ទំនង ប៊ូ ឈុំ** Chumbou2020@gmail.com

ទូរស័ព្ទ 016 509 779/ 011 435 441/ 097 990 6244

# អារម្ភកថា

វិញ្ញាណបរិសុទ្ធ ជាប្រធានបទមួយ ដែលពួកគ្រីស្ទាន ឬគ្រីស្តបរិស័ទ មិនយល់តាមសេចក្តីពិត ដែលព្រះគម្ពីរបានចែង។ នៅឆ្នាំ៣៨១ គ. ស. ទីប្រឹក្សារបស់អធិរាជកុងស្តិនទីន (Constantine) បង្កើតគោលលទ្ធិព្រះត្រៃឯកព្រះមានបីអង្គគឺព្រះវរបិតា ព្រះរាជបុត្រា នឹងព្រះវិញ្ញាណបរិសុទ្ធ។ បទព្រះគម្ពីរ តាមឯកសារដើម ជាភាសាក្រេក មិនដែលបានចែងថា «វិញ្ញាណ» ជាតួអង្គព្រះនោះទេ។ លោកសាវកប៉ុល បានសរសេរសំបុត្រទាំង១៣ ផ្ញើទៅជំរាបសួរដល់ពួកជំនុំផងព្រះអម្ចាស់ ដោយនូវព្រះនាមព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទតែប៉ុណ្ណោះ។

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយនូវព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ» (រ៉ូម១:៧)

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយនូវព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា នឹងអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទផង» (១កូរិនថូស១:៣)

## អារម្ភកថា (ន)

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត មកអំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ» (២កូរិនថូស១:២)

«សូមឲ្យអ្នករាល់គ្នាបានប្រកប ដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា នឹងអំពីព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា» (កាឡាទី១:៣)

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ» (អេភេសូរ១:២)

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា ហើយអំពីព្រះយេស៊ូវគ្រីស្ទ» (ភីលីព១:២)

«សំបុត្រប៉ុលខ្ញុំ... ផ្ញើមកពួកបរិសុទ្ធ ជាពួកបងប្អូនស្មោះត្រង់ក្នុងព្រះគ្រីស្ទ...សូមឲ្យអ្នករាល់គ្នាបានប្រកប ដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា» (កូល៉ុស១:១-២)

## អារម្ភកថា (ត)

«...សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ» (១ថែស្សាឡូនីច១:១)

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ» (២ថែស្សាឡូនិច១:២)

«...សូមឲ្យអ្នកបានប្រកបដោយព្រះគុណ សេចក្ដីមេត្តាករុណា នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នា» (១ធីម៉ូថេ១:២)

«...សូមឲ្យអ្នកបានប្រកបដោយព្រះគុណ សេចក្ដីមេត្តាករុណា នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា ហើយអំពីព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា» (២ធីម៉ូថេ១:២)

«...សូមឲ្យអ្នកបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត មកអំពីព្រះដ៏ជាព្រះវរបិតា ហើយអំពីព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា» (ទីតុស១:៤)

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្តអំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ» (ភីលេម៉ូន១:៣)

**សំបុត្ររបស់សាវកពេត្រុស:**

«សូមឲ្យព្រះគុណ នឹងសេចក្ដីសុខសាន្ត បានចំរើនដល់អ្នករាល់គ្នាឲ្យបានស្គាល់ព្រះ...[ព្រះវរបិតា]... នឹងព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើង» (២ពេត្រុស១:២)

**សំបុត្ររបស់សាវកយ៉ូហាន:**

«ដូច្នេះ សេចក្ដីដែលយើងខ្ញុំបានឃើញ ហើយឮនោះ យើងខ្ញុំប្រាប់មកអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាមានសេចក្ដីប្រកបនឹងយើងខ្ញុំដែរ រីឯសេចក្ដីប្រកបរបស់យើងខ្ញុំ នោះគឺប្រកបនឹងព្រះវរបិតា ហើយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាទ្រង់» (១យ៉ូហាន១:៣)

«....ឯសេចក្ដីពិត គឺជាព្រះបន្ទូលរបស់ទ្រង់» (យ៉ូហាន១៧:១៧)

ប៊ូ ឈុំ

២០២៣

# វិញ្ញាណបរិសុទ្ធនៃព្រះ The Holy Spirit of God

វិញ្ញាណមិនមែនជាតួអង្គព្រះទេ ហើយក៏មិនមែនជាសមាជិកទីបីនៃព្រះត្រៃឯកដែរ។ លោកសាវកយ៉ូហានបានសរសេរថា «...ក៏មានចង្កៀង៧នេះនៅពីខាងមុខ នោះគឺជាវិញ្ញាណទាំង៧របស់ព្រះ» (វិវរណៈ៤:៥) លោកសាវកប៉ុលបានសរសេរថា «តើទេវតាទាំងនោះមិនមែនជាវិញ្ញាណបំរើ ដែលទ្រង់បានចាត់មក សំរាប់ការជំនួយ ដល់ពួកអ្នកដែលត្រូវទទួលសេចក្ដីសង្គ្រោះជាមរដកទេឬអី?» (ហេព្រើរ១:១៤) សាវកយ៉ូហានបន្តសរសេរថា «...ឯភ្នែកទាំងនោះគឺជាវិញ្ញាណទាំង៧របស់ព្រះ ដែលទ្រង់ចាត់ទៅពេញលើផែនដី» (វិវរណៈ៥:៦) វិញ្ញាណបរិសុទ្ធរបស់ព្រះ គឺជាអំណាច ព្រះចេស្ដា ដែលព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវប្រើ ដើម្បីសំរេចគ្រប់ការនៃសេចក្ដីសង្គ្រោះដល់មនុស្ស ទៅតាមព្រះហឫទ័យទ្រង់។ ព្រះដ៏ព្រះវរបិតាទ្រង់ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដោយឥតគិតថ្លៃដល់អស់អ្នកណាដែលប្រែចិត្តពីអំពើបាប ដោយស្មោះត្រង់ ហើយទទួលបុណ្យជ្រមុជទឹក គឺជ្រមុជខ្លួនទៅក្នុងទឹកទាំងស្រុង កាលណាឡើងពីទឹកវិញ ដោយការដាក់ដៃលើអធិស្ឋាន ដើម្បី

ឲ្យអ្នកអាចទទួលបានអំណោយទានជាវិញ្ញាណបរិសុទ្ធមកសណ្ឋិតនៅក្នុងចិត្ត នឹងសេចក្តីសន្យាពីជីវិតអស់កល្បជានិច្ច តាមរយៈសេចក្តីជំនឿ ជឿព្រះយេស៊ូវគ្រីស្ទ។ វិញ្ញាណបរិសុទ្ធរបស់ព្រះ គឺជាអំណាចរបស់ព្រះអង្គ ដែលទ្រង់ប្រទានដល់កូនប្រុស កូនស្រីរបស់ព្រះអង្គម្នាក់ៗ ដើម្បីឲ្យមានចំណែកជាមួយនឹងព្រះយេស៊ូវគ្រីស្ទ បានចំរើនទូវសេចក្តីស្រឡាញ់របស់ព្រះ មានអំណរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត។ វិញ្ញាណបរិសុទ្ធរបស់ព្រះ ផ្តល់អំណាចឲ្យកូនរបស់ព្រះអង្គម្នាក់ៗ នូវអំណាចដែលអាចរស់នៅទៅតាមព្រះហឫទ័យរបស់ព្រះ ហើយនឹងអាចយកជ័យជំនះ លើសេចក្តីល្បួង ដែលកើតមកពីនិស្ស័យរបស់មនុស្សពីកំណើត នឹងពីអារក្សសាតាំង។ អស់អ្នកដែលមានវិញ្ញាណរបស់ព្រះសណ្ឋិតនៅជាមួយ តែងតែស្តាប់បង្គាប់តាមព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដើម្បីឲ្យបានបំរើព្រះអម្ចាស់ដោយវិញ្ញាណ នឹងសេចក្តីពិត ប្រយោជន៍ឲ្យកូនប្រុស កូនស្រីរបស់ព្រះអង្គទទួលបានសេចក្តីសង្គ្រោះ។

លោកុប្បត្តិ១:២ «ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធងងឹតនៅគ្របលើជំរៅទឹក ហើយវិញ្ញាណបរិសុទ្ធនៃព្រះក៏រេរានៅពីលើទឹក» **បើវិញ្ញាណ ជាតួអង្គព្រះ តើអាចរេរានៅពីលើទឹកបានដែរឬទេ? មិនបានទេ! ដូច្នេះ វិញ្ញាណមិនមែនជាតួអង្គព្រះ ឬក៏**

ជាសមាជិកទី៣ នៃគ្រួសារព្រះនោះទេ!

យ៉ូហាន១៤:១៦, ២៦ ព្រះយេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា «នោះខ្ញុំ...[ព្រះយេស៊ូវ]...នឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានជំនួយមួយមកអ្នករាល់គ្នា ឲ្យបាននៅជាមួយ នៅអស់កល្បរៀងទៅ...គឺជាវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មកដោយនូវឈ្មោះខ្ញុំ នោះទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្តីទាំងអស់ ក៏រំឭកពីគ្រប់ទាំងសេចក្តី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ» លោកសាវកប៉ុលសរសេរថា ១៩.«ដូចមានសេចក្តីចែងទុកមកថា សេចក្តីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយមិនដែលគិតដល់ គឺសេចក្តីនោះឯងដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់ ១១០. ព្រះទ្រង់បានសំដែងឲ្យយើងរាល់គ្នាឃើញ សេចក្តីទាំងនោះ ដោយសារវិញ្ញាណទ្រង់ ដ្បិតវិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ ព្រមទាំងសេចក្តីជ្រាលជ្រៅនៃព្រះដែរ ១១១. ដ្បិតបើមិនមែនជាវិញ្ញាណ ដែលនៅក្នុងខ្លួនមនុស្សទេ នោះតើមានអ្វីនឹងស្គាល់សណ្ដានមនុស្សនោះបាន ហើយបើមិនមែនជាវិញ្ញាណបរិសុទ្ធនៃព្រះ នោះក៏គ្មានអ្នកណាស្គាល់សណ្ដានព្រះបានដែរ ១១២. ឯយើងរាល់គ្នាយើងមិនបានទទួលវិញ្ញាណរបស់លោកីយទេ គឺទទួលវិញ្ញាណបរិសុទ្ធដែលមកពីព្រះវិញ ដើម្បីឲ្យបានស្គាល់អស់ទាំងព្រះគុណ

ដែលព្រះបានផ្តល់មកយើង ១៣. ហើយយើងក៏និយាយពីសេចក្តីទាំងនោះឯង មិនមែនដោយពាក្យសំដី ដែលប្រាជ្ញាមនុស្សបានបង្រៀនទេ គឺដោយពាក្យសំដី ដែលវិញ្ញាណបរិសុទ្ធបង្រៀនវិញ ព្រមទាំងផ្ទឹមពន្យល់សេចក្តីខាងឯវិញ្ញាណ ដោយសេចក្តីខាងឯវិញ្ញានផង ១៤. ប៉ុន្តែ មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯវិញ្ញាណបរិសុទ្ធនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រូវឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ ១៥. ឯមនុស្សខាងវិញ្ញាណវិញ គេពិចារណាយល់គ្រប់ទាំងអស់បាន តែមិនត្រូវអ្នកណាពិចារណាខ្លួនឡើង ១៦. ដ្បិតតើអ្នកណាបានស្គាល់គំនិតនៃព្រះអម្ចាស់ តើអ្នកណានឹងបង្រៀនទ្រង់បាន តែយើងរាល់គ្នាមានគំនិតជារបស់ផងព្រះគ្រីស្ទវិញ» (១កូរិនថូស២:៩-១៦)

២ធីម៉ូថេ១:៦-៧ ៦. «ដោយហេតុនោះបានជាខ្ញុំរំឭកដល់អ្នក ឲ្យដាស់តឿនអំណោយទានរបស់ព្រះ ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ...[អធិស្ឋានដាក់ដៃលើ]...៧. ដ្បិតព្រះទ្រង់មិនបានប្រទានឲ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឲ្យមានវិញ្ញាណដ៏មានអំណាច សេចក្តីស្រឡាញ់ នឹងប្រាជ្ញានឹងធឹងវិញ» (៦-៧)

២កូរិនថូស១:២១-២២ ២១. «រីឯអ្នកដែលតាំងយើងខ្ញុំ

ឲ្យខ្ជាប់ខ្លួនក្នុងព្រះគ្រីស្ទ ជាមួយនឹងអ្នករាល់គ្នា ហើយដែលចាក់ប្រេងឲ្យយើង នោះគឺជាព្រះ ១២២. ទ្រង់ក៏បានដៅចំណាំយើងរាល់គ្នា ហើយបានប្រទានវិញ្ញាណបរិសុទ្ធមកបញ្ចាំចិត្តយើងរាល់គ្នាផង» (១២១-២២)

កិច្ចការ២:៣៧-៣៨ នៅឯបុណ្យថ្ងៃទី៥០ នៅក្រុងយេរូសាឡឹម មានពួកសាសន៍យូដា មកពីគ្រប់នគរនៅក្រោមមេឃ មកចូលរួមធ្វើបុណ្យថ្ងៃទី៥០ ពួកគេក៏ឮទីបន្ទាល់ ពីការអស្ចារ្យ ដែលព្រះអម្ចាស់ទ្រង់បានធ្វើតាមរយៈពួកសាវក ហេតុនោះបានជាពួកសាសន៍ ក៏មកឯពួកសាវក ហើយសួរថា ២៣៧. «...បងប្អូនអើយ តើយើងខ្ញុំត្រូវធ្វើដូចម្តេច ២៣៨. ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្ត ...[ប្រែចិត្តពីអំពើបាប]...ចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាវិញ្ញាណបរិសុទ្ធរបស់ព្រះ» (២៣៧-៣៨) សាវកប៉ុលបានសរសេរថា វិញ្ញាណបរិសុទ្ធនោះ គឺជាអំណាចរបស់ព្រះដែលទ្រង់ប្រទានដល់អស់អ្នកដែលប្រែចិត្តពីអំពើបាប ហើយជឿព្រះយេស៊ូវគ្រីស្ទ រ៉ូម៨:៩-១៤ ២៩. «តែបើសិនជាវិញ្ញាណបរិសុទ្ធនៃព្រះសណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះអ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ គឺនៅខាងវិញ្ញាណវិញ ប៉ុន្តែ បើអ្នកណាគ្មានវិញ្ញាណបរិសុទ្ធរបស់ព្រះ

គ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ ១០. ហើយបើសិនជាព្រះគ្រីស្ទសណ្ឋិត... [ដោយវិញ្ញាណ]... ក្នុងអ្នករាល់គ្នា នោះរូបសាច់បានស្លាប់ ដោយព្រោះអំពើបាបមែន តែវិញ្ញាណមានជីវិតវិញ ដោយព្រោះសេចក្តីសុចរិត ១១. មួយទៀត បើវិញ្ញាណបរិសុទ្ធនៃព្រះអង្គ...[វិញ្ញាណបរិសុទ្ធនៃព្រះវរបិតា]...ដែលបានប្រោសឲ្យព្រះគ្រីស្ទរស់ពីស្លាប់ឡើង ទ្រង់នឹងប្រោសរូបកាយនៃអ្នករាល់គ្នាដែលទៀងតែស្លាប់ ឲ្យមានជីវិតឡើងដែរ ដោយសារវិញ្ញាណបរិសុទ្ធទ្រង់ ដែលសណ្ឋិតនៅក្នុងខ្លួនអ្នករាល់គ្នា ១២. ដូច្នេះ បងប្អូនអើយ យើងមានសេចក្តីជាប់ជំពាក់ មិនមែនជំពាក់ចំពោះសាច់ឈាមឲ្យបានរស់តាមសាច់ឈាមនោះទេ ១៣. ដ្បិតបើសិនអ្នករាល់គ្នារស់តាមសាច់ឈាម នោះនឹងត្រូវស្លាប់ទៅ តែបើសំឡាប់អំពើរបស់រូបសាច់ចេញ ដោយសារវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នានឹងបានរស់វិញ ១៤. ហើយអស់អ្នកណាដែលវិញ្ញាណបរិសុទ្ធនៃព្រះនាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ» (៩-១៤)

លោកលូកាបានសរសេរ ពីពួកសាវកនៅក្រុងយេរូសាឡិមថា បន្ទាប់ពីពួកគេបានឮ ថាសាសន៍ដទៃបានទទួលព្រះបន្ទូល កិច្ចការ ៨:១៤-១៧ ១៤. «កាលពួកសាវក នៅក្រុងយេរូសាឡិម បានឮថាស្រុកសាម៉ារីទទួលព្រះបន្ទូលហើយ នោះគេចាត់ពេត្រុស នឹងយ៉ូហានឲ្យទៅឯអ្នកនោះ ១៥. លុះអ្នកទាំងពីរបានចុះទៅដល់ហើយ នោះ

ករបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ សំរាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់» (១១៣-១៤)

## មានភ័ស្តុតាងជាច្រើន បានបញ្ជាក់ថាព្រះទ្រង់មិនមែនជាព្រះត្រៃឯង

## ប្រវត្តិសាស្រ្តបញ្ជាក់

១) ព្រះត្រៃឯកបានបង្កើតឡើង រាប់រយឆ្នាំ បន្ទាប់ពីព្រះគម្ពីរសញ្ញាថ្មីបានសរសេរ ហើយរៀបចំចប់សព្វគ្រប់។

២) គោលលទ្ធិព្រះត្រៃឯង បានបង្កើតឡើង ដោយក្រុមទីប្រឹក្សារបស់អធិរាជកុងស្តិនទីន នៅឆ្នាំ៣៨១ គ្រីសសករាជ (381 AD)

៣) នៅសតវត្សរ៍ទី២ នៃគ្រិសសករាជ គេបានបន្ថែម បញ្ចូលសេចក្តីមិនត្រឹមត្រូវ ទៅក្នុងគម្ពីរសំបុត្រយ៉ូហានទី១ ជំពូក៥:៧ «...នៅស្ថានសួគ៌ គឺជាព្រះវរបិតា១ ព្រះបន្ទូល១ នឹងព្រះវិញ្ញាណបរិសុទ្ធ១ តែទាំង៣អង្គនេះរួមមកតែ១ទេ Peake's Commentary វចនានុក្រម Peake's នៃព្រះគម្ពីរ សរសេរថា «តាមឯកសារដើម ជាភាសាក្រេក មិនបានចែងថា វិញ្ញាណជាតួអង្គព្រះទេ។ វចនានុក្រម ព្រះគម្ពីរមួយចំនួនធំ យល់ព្រមថា វិញ្ញាណមិនមែនជាតួអង្គព្រះទេ។ គម្ពីរបកប្រែថ្មីៗជាច្រើនបានលុបចោលឯកសារដើជាភាសាក្រេក ទាំងស្រុង។

១យ៉ូហាន៥:៦-៧ គួរបានអានយ៉ាងនេះវិញ «គឺព្រះយេស៊ូវ

ក៏អធិស្ឋានឲ្យគេ ប្រយោជន៍ឲ្យគេបានទទួលវិញ្ញាណបរិសុទ្ធនៃព្រះ ខ១៦. ដ្បិតវិញ្ញាណបរិសុទ្ធនៃព្រះមិនទាន់ចុះមកសណ្ឋិតលើពួកគេណាមួយនៅឡើយ គេគ្រាន់តែបានទទួលបុណ្យជ្រមុជ ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូវប៉ុណ្ណោះ ខ១៧. ដូច្នេះ អ្នកទាំងពីរក៏ដាក់ដៃលើ...[ អធិស្ឋាន]...គេ ហើយគេបានទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះដែរ» ( ខ១៤-១៧)

វិញ្ញាណបរិសុទ្ធរបស់ព្រះបានប្រទានមកអស់អ្នក ដែលប្រែចិត្តពីអំពើបាប ទទួលបុណ្យជ្រមុជទឹក ដោយការអធិស្ឋានដាក់ដៃលើ ព្រះដ៏ជាព្រះវរបិតាទ្រង់នឹងប្រទានវិញ្ញាណរបស់ទ្រង់មកក្នុងចិត្តកូនប្រុស កូនស្រីរបស់ទ្រង់ ដើម្បីរៀបចំគេ សំរាប់ប្រោសឲ្យរស់ពីស្លាប់ឡើងវិញ នៅពេលព្រះយេស៊ូវយាងមកផែនដីនេះ ជាលើកទី២។

វិញ្ញាណបរិសុទ្ធមិនមែនជាតួអង្គព្រះទេ បើវិញ្ញាណបរិសុទ្ធជាតួអង្គព្រះ នោះមិនអាចនៅក្នុងមនុស្ស ឬក៏ដៅចំណាំនៅក្នុងចិត្តមនុស្សបានទេ។ អេភេសូរ១:១៣-១៤ ខ១៣. «ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ខ១៤. វិញ្ញាណបរិសុទ្ធនោះជាទីបញ្ចាំចិត្ត ពីដំណើរគេរ្តីអា

គ្រីស្ទនេះហើយ ដែលយាងមកដោយទឹក ហើយនឹងឈាម មិនមែនដោយទឹកតែប៉ុណ្ណោះទេ គឺទាំងទឹកទាំងឈាមផង គឺជាវិញ្ញាណដែលធ្វើបន្ទាល់ ដ្បិតវិញ្ញាណបរិសុទ្ធនៃព្រះ ជាសេចក្តីពិត មានសាក្សី៣ធ្វើបន្ទាល់នៅផែនដី គឺវិញ្ញាណ១ ទឹក១ ហើយនឹងឈាមទាំងបីរួមមកតែ១» (៥៦-៧)

## ភ័ស្តុតាងក្នុងបទគម្ពីរ

១) ពាក្យ «ព្រះត្រៃឯង» មិនមាននៅក្នុងបទគម្ពីរទេ

២) វិញ្ញាណបរិសុទ្ធរបស់ព្រះ «ត្រូវបានចាក់» នៅថ្ងៃបុណ្យទី៥០... ទៅលើទាំងពួកអ្នកបំរើប្រុស ស្រីផង គម្ពីរកិច្ចការ ១០:៤៥ «...អំណោយទាន ជាវិញ្ញាណបរិសុទ្ធ បានចាក់មកពូលើពួកសាសន៍ដទៃ...» **បើវិញ្ញាណជាតួអង្គព្រះមិនអាចចាក់ចេញបានទេៗ**

៣) កិច្ចការ២:២ «ស្រាប់តែមានឮសូរពីលើមេឃ ដូចជាខ្យល់បក់គំហុកយ៉ាងខ្លាំង មកពេញក្នុងផ្ទះដែលគេអង្គុយនៅ» បើសិនជាតួអង្គព្រះ មិនមានឮដូចជាខ្យល់បក់មកពេញក្នុងផ្ទះនោះទេ

៤) បើវិញ្ញាណជាតួអង្គព្រះ «ក៏មិនមានអណ្តាត ដូចជាអណ្តាតភ្លើង....» ដែលមនុស្សមិនអាចធ្វើបាន (កិច្ចការ២:៣)

៥) ព្រះគ្រីស្ទមានគភ៌ ដោយវិញ្ញាណបរិសុទ្ធ

(ម៉ាថាយ១:១៨, ២០) បើវិញ្ញាណបរិសុទ្ធជាតួអង្គព្រះ នោះវិញ្ញាណបរិសុទ្ធ ជាព្រះវរបិតារបស់ព្រះយេស៊ូវគ្រីស្ទ!

៦) វិញ្ញាណបរិសុទ្ធ មិនមែនជាតួអង្គព្រះទេ គឺជាអំណាចរបស់ព្រះ ដែលទ្រង់ប្រើ ដើម្បីសំរេចផែនការរបស់ទ្រង់។

៧) ពេលខ្លះបទគម្ពីរបានបញ្ជាក់លក្ខណៈដូចជាមនុស្ស «ប្រាជ្ញាតែងបន្លឺឡើងនៅក្នុងផ្លូវ ក៏បញ្ចេញសំឡេងនៅទីធ្លា» (សុភាសិត១:២០-៣៣) ឧទាហរណ៍មួយទៀត "ពាក្យស្វែងយល់" «អើ បើឯងស្រែកហៅកដំរិះ ព្រមទាំងបន្លឺសំឡេងឡើង សូមឲ្យបានយោបល់ បើឯងខំរកដូចជារកប្រាក់ ហើយស្វែងរកដូចជារកកំណប់ទ្រព្យ» (សុភាសិត២:៣-៤) ដោយការប្រើពាក្យ «ឯង» មិនអាចធ្វើឲ្យដំរិះ នឹង យោបល់ ទៅជាតួអង្គមនុស្សបានឡើយ។

៨) ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថាខ្ញុំហើយនឹងព្រះវរបិតា គឺតែមួយព្រះអង្គទេ (យ៉ូហាន១០:៣០; ១៧:២១-២២) ព្រះយេស៊ូវមិនដែលមានបន្ទូលថា វិញ្ញាណបរិសុទ្ធ គឺតែមួយ ជាមួយនឹងទ្រង់ ហើយនឹងព្រះវរបិតានៃទ្រង់នោះទេ។

៩) «ព្រះយេហូវ៉ាទ្រង់មានបន្ទូល ដល់ព្រះអម្ចាស់...[ព្រះយេស៊ូវ]...នៃទូលបង្គំថា ចូរឲ្យឯងអង្គុយនៅខាងស្តាំអញ...»(ទំនុកដំកើង១១០:១) ព្រះអង្គមានបន្ទូលពីហ្វូងដាវីឌថា «...ជាទីគាប់ចិត្តអញ ដែលនឹងធ្វើតាមចិត្តអញគ្រប់ជំពូក» (កិច្ចការ១៣:

២២) ហ្វូងដាវិឌបានសរសេរថា ព្រះមានតែពីរព្រះអង្គ។

១០) ម៉ាថាយ២៨:១៩ «ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា នឹងវិញ្ញាណបរិសុទ្ធនៃព្រះចុះ» ការប្រើពាក្យ «វិញ្ញាណបរិសុទ្ធរបស់ព្រះ» នោះមិនអាចនឹងធ្វើឲ្យវិញ្ញាណបរិសុទ្ធ ទៅជាតួអង្គនៃព្រះបានទេ។

១១) សំបុត្ររបស់សាវកប៉ុលទាំង១៣ ដែលផ្ញើទៅជំរាបសួរពួកជំនុំ ក្នុងព្រះនាមព្រះដ៏ជាព្រះវរបិតា នឹងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទតែប៉ុណ្ណោះ ឥតមានក្នុងនាមព្រះវិញ្ញាណទេ!

ក. រ៉ូម១:៧ «...សូមឲ្យអ្នករាល់គ្នាបានប្រកបដោយនូវព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ»

ខ. ១កូរិនថូស១:៣ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយនូវព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា នឹងអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទផង»

គ. ២កូរិនថូស១:២ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត មកអំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ»

ឃ. កាឡាទី១:៣ «សូមឲ្យអ្នករាល់គ្នាបានប្រកប ដោយ

ព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា នឹងពី ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»

ង. អេភេសូរ១:២ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពី ព្រះអម្ចាស់យេស៊ូវគ្រីស្ទ»

ច. ភីលីព១:២ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្តីសុខសាន្ត អំព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា ហើយ អំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ»

ឆ. កូល៉ុស១:២ «សំបុត្រប៉ុលខ្ញុំ... នឹងធីម៉ូថេ... ផ្ញើមកពួក បរិសុទ្ធ ជាពួកបងប្អូនស្មោះត្រង់ក្នុងព្រះគ្រីស្ទ... សូមឲ្យអ្នករាល់គ្នា បានប្រកប ដោយព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះ វរបិតានៃយើងរាល់គ្នា»កកក

ជ. ១ថែស្សាឡូនីច១:១ «...សូមឲ្យអ្នករាល់គ្នាបានប្រកប ដោយព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃ យើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ»

ឈ. ២ថែស្សាឡូនីច១:២ «សូមឲ្យអ្នករាល់គ្នាបានប្រកប ដោយព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ»

ញ. ១ធីម៉ូថេ១:២ «...សូមឲ្យអ្នកបានប្រកបដោយព្រះ

គុណ សេចក្តីមេត្តាករុណា នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»

ជ. ២ធីម៉ូថេ១:២ «...សូមឲ្យអ្នកបានប្រកបដោយព្រះគុណ សេចក្តីមេត្តាករុណា នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា ហើយអំពីព្រះព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»

ឋ. ទីតុស១:៤ «...សូមឲ្យអ្នកបានប្រកបដោយព្រះគុណ នឹងសេចក្តីសុខសាន្ត មកអំពីព្រះដ៏ជាព្រះវរបិតា ហើយអំពីព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា»

ឌ. ភីលីម៉ូន១:៣ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ»

ឍ. សាវកពេត្រុស បានសរសេរថា ព្រះមានតែពីរអង្គ ២ពេត្រុស១:២ «សូមឲ្យព្រះគុណ នឹងសេចក្តីសុខសាន្ត បានចំរើនដល់អ្នករាល់គ្នាឲ្យបានស្គាល់ព្រះ...[ព្រះវរបិតា]... នឹងព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើង»

ណ. សាវកយ៉ូហាន ជាសាវកដែលព្រះយេស៊ូវស្រឡាញ់លើសជាងសាវកឯទៀតនោះ បានសរសេរថា ព្រះមានតែពីរព្រះអង្គ ១យ៉ូហាន១:៣ «ដូច្នេះ សេចក្តីដែលយើងខ្ញុំបានឃើញ

ហើយពួនោះ យើងខ្ញុំប្រាប់មកអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាមាន សេចក្តីប្រកបនឹងយើងខ្ញុំដែរ រីឯសេចក្តីប្រកបរបស់យើងខ្ញុំ នោះគឺ ប្រកបនឹងព្រះវរបិតា ហើយនឹងព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រា ទ្រង់»

គ. សាវកយ៉ូហានបានសរសេរថា វិញ្ញាណមិនមែនជាតួអង្គ ព្រះទេ វិវរណៈ២:៤ «...ក៏មានចង្កៀង៧ឆេះនៅពីខាងមុខ នោះគឺ ជាវិញ្ញាណទាំង៧របស់ព្រះ» វិវរណៈ៥:៦ «ខ្ញុំ...[សាវកយ៉ូហាន]... ក្រឡេកទៅឃើញមានកូនចៀម១ ដែលមើលទៅដូចជាបានសំឡាប់ ហើយ មានទាំងស្នែង៧ នឹងភ្នែក៧... ឯភ្នែកទាំងនោះ គឺជាវិញ្ញាណ ទាំង៧របស់ព្រះ ដែលទ្រង់ចាត់ទៅពេញលើផែនដី»

១២) សាសនារបស់អារក្សសាតាំង បង្រៀនថាព្រះមានបី អង្គ គឺព្រះវរបិតា ព្រះរាជបុត្រា នឹងព្រះវិញ្ញាណបរិសុទ្ធ។

***តើវិញ្ញាណបរិសុទ្ធ ត្រូវបានគេរាប់បញ្ចូល មកក្នុងពួកជំនុំ សាលកយ៉ាងដូចម្តេច?***

ក្រោមអំណាចរបស់អធិរាជ កុងស្ទិនទីន Constantine នៅឆ្នាំ ៣៨១ គ. ស. ទីប្រឹក្សារបស់អធិរាជកុងស្តិនទីន បានបង្កើតគោលលទ្ធិ ព្រះត្រៃឯក ព្រះមានបីអង្គ គឺព្រះវរបិតា ព្រះរាជបុត្រា នឹងព្រះ វិញ្ញាណបរិសុទ្ធ។ បទព្រះគម្ពីរ តាមឯកសារដើម ជាភាសាក្រេកមិន ដែលបានចែងថា «វិញ្ញាណ» នោះជាព្រះ ម្តងណាសោះឡើយ។

១៣) ព្រះអម្ចាស់ទ្រង់ជាគ្រួសារ។ ព្រះអម្ចាស់ ភាសាហេព្រើរ គឺអេឡូហ៊ីម ជាពហុវចនៈ មានន័យថា ច្រើនជាមួយ។ ព្រះអម្ចាស់ជាគ្រួសារបរិសុទ្ធ ដែលមានពេញដោយព្រះចេស្តា និងភាពវៃឆ្លាត ជាគ្រួសារដែលស្ថិតនៅអស់កល្បជានិច្ច ជាគ្រួសារបរិសុទ្ធល្អឥតខ្ចោះ គ្រប់លក្ខណ៍ សុចរិតគ្រប់យ៉ាង ពេញដោយសេចក្តីស្រឡាញ់ មានគោលបំណងល្អនៅអស់កល្ប។ គ្រួសាររបស់ព្រះអម្ចាស់ជាអង្គបង្កើតច្បាប់ បង្កបង្កើតរបស់សព្វសារពើ ជាអង្គទ្រទ្រង់នូវសារៈធាតុ នឹងគ្រប់គ្រងលោកីយទាំងមូល នឹងអស់ទាំងជីវិត នៅអស់កល្ប បទគម្ពីរបានចែងថា «ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចជាយើង.... ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេ» (លោកុប្បត្តិ១:២៦-២៧) ហេតុនេះហើយ ព្រះអម្ចាស់ទ្រង់មានលក្ខណៈដូចមនុស្សដែលទ្រង់បង្កើតឡើង។ ព្រះអម្ចាស់មានពីរ(២) អង្គ គឺព្រះដ៏ជាព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រា។ សមាជិកគ្រួសារទាំងពីរអង្គនេះ «មានលក្ខណៈតែមួយ ឬ ភាពដំណាង នឹង លក្ខណៈដូច» ហើយទ្រង់ក៏ប្រទានឲ្យមនុស្ស មានភាពយ៉ាងដូច្នោះដែរ។ ព្រះអម្ចាស់ទ្រង់មានគោលបំណងដ៏ធំបំផុត គឺពង្រីកគ្រួសាររបស់ទ្រង់ តាមផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់ ដោយទ្រង់សព្វព្រះហឫទ័យប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់

ដល់អស់អ្នកណាដែលប្រែចិត្តពីអំពើបាប ជឿដល់ព្រះយេស៊ូវគ្រីស្ទ ទទួលបុណ្យជ្រមុជទឹក ហើយទទួលបានវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា នឹង វិញ្ញាណបរិសុទ្ធរបស់ព្រះយេស៊ូវគ្រីស្ទ មកបញ្ចាំងក្នុងចិត្ត រស់នៅដោយសារគ្រប់ទាំងព្រះបន្ទូលចេញពីព្រះឱស្ឋព្រះមក កាន់ខ្ជាប់តាមសេចក្ដីជំនឿ ដរាបដល់ចុងបំផុត នោះយើងនឹងត្រូវប្រោសឲ្យរស់ពីស្លាប់ឡើងវិញ [រស់ជាវិញ្ញាណ] នៅពេលព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់យាងត្រឡប់មកផែនដីនេះវិញ។

ព្រះគម្ពីរបានសំដែងយ៉ាងច្បាស់ថា មនុស្សស្លាប់ នឹងរស់ឡើងវិញជាពិត «...ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញជាពិត ជាផលដំបូងពីពួកដែលបានដេកលក់ទៅហើយ ដ្បិតដែលសេចក្ដីស្លាប់បានមកដោយសារមនុស្ស នោះសេចក្ដីដែលមនុស្សស្លាប់បានរស់ឡើងវិញ ក៏មកដោយសារមនុស្សដែរ ព្រោះ ដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណានោះ នោះគ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ» (១កូរិនថូស១៥:២០-២២)

លោកសាវកប៉ុលបានសរសេរថា ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ មុនគេបង្អស់ គឺជាផលដំបូងពីពួកអ្នកដែលស្លាប់ទៅហើយ «នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្ដីអាថ៌កំបាំង គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ តែទាំងអស់គ្នានឹងបាន

ផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ» (១កូរិនថូស១៥:៥១-៥២)

ការរស់ពីស្លាប់ឡើងវិញ គឺជាសេចក្តីសង្ឃឹមដ៏ចំបងទីមួយរបស់ពួកអ្នកគ្រីស្ទានពិត គឺជាកំណើតថ្មី ឬការកើតជាថ្មី ខាងវិញ្ញាណ ដោយការប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ដោយអំណាចព្រះចេស្តារបស់ព្រះវរបិតា ដែលទ្រង់មានផែនការសង្គ្រោះមនុស្សតាំងពីកំណើតលោកីយមក ដើម្បីឲ្យមនុស្សទាំងអស់បានទទួលជីវិតអស់កល្បរស់នៅក្នុងនគរព្រះ។

បទគម្ពីរយោង:

១. វិវរណៈ៤-៥
២. វិវរណៈ៥-៦
៣. លោកុប្បត្តិ១:២
៤. យ៉ូហាន១៤:១៦, ២៦
៥. ១កូរិនថូស២:១៦
៦. ២ធីម៉ូថេ១:៦-៧
៧. ២កូរិនថូស១:២១-២២
២១. យ៉ូហាន១៧:២១-២២
២២. ទំនុក. ១១០:១
២៣. ម៉ាថាយ២៨:១៩
២៤. រ៉ូម១:៧
២៥. ១កូរិនថូស១:២
២៦. ២កូរិនថូស១:២
២៧. កាឡាទី១:៣

បទគម្ពីរយោង (ត)

៨. កិច្ចការ២:៣៧-៣៨
៩. រ៉ូម៨:៩-១៤
១០. កិច្ចការ៨:១៤-១៧
១១. អេភេសូរ១:១៣-១៤
១២. ១យ៉ូហាន៥:៦-៧
១៣. កិច្ចការ១០:៤៥
១៤. កិច្ចការ២:២
១៥. កិច្ចការ២:៣
១៦. ម៉ាថាយ១:១៨-២០
១៧. សុភាសិត១:២០-៣៣
១៨. សុភាសិត២:៣-៤
១៩. យ៉ូហាន១០:៣០
២០. យ៉ូហាន១៧:២១-២២
២៨. អេភេសូរ១:២
២៩. ភីលីព១:២
៣០. កូល៉ុស១:២
៣១. ១ថែស្សា. ១:១
៣២. ២ថែស្សា.១:២
៣៣. ១ធីម៉ូថេ១:២
៣៤. ២ធីម៉ូថេ១:២
៣៥. ទីតុស១:៤
៣៦. ភីលីម៉ូន១:៣
៣៧. ២ពេត្រុស១:២
៣៨. ១យ៉ូហាន១:៣
៣៩. លោកុ. ១:២៦-២៧
៤០. ១កូរិន. ១៥:២០-២១
៤១. ១កូរិន. ១៥:៥១-៥២